# ព្រះរាជក្រម

នស/រកម/០៧២៣/ ០១១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិធានដើមកំណើតទំនិញ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៣ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅៈ

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្តីពី

# វិធានដើមកំណើតទំនិញ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា១ _ គោលបំណង**

ច្បាប់នេះកំណត់អំពីគោលការណ៍និងវិធានដើមកំណើតនៃទំនិញនាំចេញនិងទំនិញនាំចូល ក្នុងគោលបំណងជំរុញនិងសម្រួលពាណិជ្ជកម្មដែលទទួលបានប្រយោជន៍ពីការអនុគ្រោះពាណិជ្ជកម្ម និងការអនុវត្តក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ព្រមទាំងចូលរួមទប់ស្កាត់ការក្លែងបន្លំដើមកំណើតទំនិញ។

**មាត្រា២ _ វិសាលភាព**

ច្បាប់នេះមានវិសាលភាពអនុវត្តលើវិធានដើមកំណើតទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងវិធានដើមកំណើតទំនិញក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងត្រូវអនុវត្តចំពោះ៖

១- ផលិតករនិងអ្នកនាំចេញនាំចូល ដែលមានតម្រូវការសំអាងដើមកំណើតទំនិញនិងស្លាកសញ្ញាសម្គាល់ដើមកំណើតផលិតផល។

២- អាជ្ញាធរចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញនៃទំនិញនាំចេញ។

៣- អាជ្ញាធរទទួលសំអាងដើមកំណើតទំនិញនៃទំនិញនាំចូល។

៤- នីតិបុគ្គលឬស្ថាប័នដែលចូលរួមក្នុងសកម្មភាពពាណិជ្ជកម្ម ដែលធ្វើប្រតិវេទន៍ដើមកំណើតទំនិញ។

**មាត្រា៣ _ និយមន័យ**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១- **វិធានដើមកំណើតទំនិញ** សំដៅដល់វិធានដើមកំណើតទំនិញឬវិធានប្រភពដើមទំនិញ ដែលមានវិធានដើមកំណើតទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មនិងវិធានដើមកំណើតទំនិញក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម។

២- **វិធានដើមកំណើតទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម** សំដៅដល់វិធានកំណត់ដើមកំណើតទំនិញ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រវាងប្រទេសពីរឬច្រើន អនុលោមតាមកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយនិងពាណិជ្ជកម្មឆ្នាំ១៩៩៤ របស់អង្គការពាណិជ្ជកម្មពិភពលោក ឬកិច្ចព្រមព្រៀងអនុគ្រោះពាណិជ្ជកម្មនានា។

៣- **វិធានដើមកំណើតទំនិញក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម** សំដៅដល់វិធានកំណត់ដើមកំណើតនៃទំនិញនាំចេញនិងទំនិញនាំចូល សម្រាប់អនុវត្តគោលការណ៍ប្រព្រឹត្តកម្មប្រជាជាតិដែលទទួលបានការអនុគ្រោះបំផុត ពន្ធប្រឆាំងការលក់បង្ខូចថ្លៃ ពន្ធប៉ះប៉ូវ និងវិធានការការពារ លក្ខខណ្ឌតម្រូវក្នុងការកំណត់ដើមកំណើតទំនិញ ការរឹតត្បិតបរិមាណ លទ្ធកម្មរដ្ឋាភិបាល និងការប្រមូលស្ថិតិពាណិជ្ជកម្ម។

៤- **អាជ្ញាធរទទួលសំអាងដើមកំណើតទំនិញ** សំដៅដល់រដ្ឋបាលគយដែលទទួលបានសិទ្ធិឱ្យទទួលសំអាងដើមកំណើតនៃទំនិញនាំចូល។

៥- **អាជ្ញាធរចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ** សំដៅដល់ក្រសួងពាណិជ្ជកម្មដែលមានអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្មឬអង្គភាពផ្សេងទៀត ដែលទទួលបានសិទ្ធិពីក្រសួងពាណិជ្ជកម្ម ក្នុងការចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញចំពោះទំនិញនាំចេញ និងគ្រប់គ្រងអ្នកនាំចេញដែលមានការចុះបញ្ជី

៦- **វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ** សំដៅដល់ទម្រង់ជាក់លាក់មួយដែលចេញដោយអាជ្ញាធរចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ និងបញ្ជាក់ថាទំនិញដែលមានក្នុងវិញ្ញាបនបត្រនោះមានដើមកំណើតនៅក្នុងប្រទេសជាក់លាក់ណាមួយ។

៧- **ប្រតិវេទន៍ដើមកំណើតទំនិញ** សំដៅដល់សេចក្តីប្រកាស ដែលធ្វើឡើងដោយអ្នកនាំចេញ ឬដោយអ្នកនាំចូល ដែលបញ្ជាក់ពីដើមកំណើតរបស់ទំនិញ ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាតិ ឬក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ឬកិច្ចព្រមព្រៀងពាណិជ្ជកម្មនានា ដែលព្រះរាជាណាចក្រកម្ពុជាជាភាគី ឬក្រោមប្រព័ន្ធអនុគ្រោះជាឯកតោភាគី។

៨- **វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម** សំដៅដល់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ដែលត្រូវបានប្រើសម្រាប់ការអនុវត្តក្នុងគោលបំណងទទួលបានការអនុគ្រោះពន្ធ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីឬកិច្ចព្រមព្រៀងពាណិជ្ជកម្មនានា ដែលព្រះរាជាណាចក្រកម្ពុជាជាភាគី ឬក្រោមប្រព័ន្ធអនុគ្រោះជាឯកតោភាគី។

៩- **វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម** សំដៅដល់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ដែលត្រូវបានប្រើសម្រាប់ការអនុវត្តក្នុងគោលបំណងមិនមែនប្រព្រឹត្តកម្មអនុគ្រោះពន្ធ។

១០- **ប្រព្រឹត្តកម្មប្រជាជាតិដែលទទួលបានការអនុគ្រោះបំផុត** សំដៅដល់គោលការណ៍មិនរើសអើងរវាងដៃគូពាណិជ្ជកម្មរបស់ប្រទេសមួយ។

១១- **សំអាងដើមកំណើតទំនិញ** សំដៅដល់ឯកសារឬការប្រកាសក្នុងទម្រង់ជាក្រដាសឬអេឡិចត្រូនិក ដែលជាភស្តុតាងបញ្ជាក់ថា ទំនិញដែលពាក់ព័ន្ធបំពេញបាននូវលក្ខណវិនិច្ឆ័យដើមកំណើតទំនិញ ក្រោមវិធានដើមកំណើតទំនិញដែលបានកំណត់។ សំអាងដើមកំណើតទំនិញ រួមមានវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញនិងប្រតិវេទន៍ដើមកំណើតទំនិញ។

១២- **ប្រទេសអន្តរការី** សំដៅដល់ប្រទេសមួយឬច្រើន ដែលទំនិញត្រូវបានដឹកជញ្ជូនឆ្លងកាត់ ក្រៅពីប្រទេសដើមកំណើតនិងប្រទេសនាំចូលចុងក្រោយ។

## ជំពូកទី២

## វិធានដើមកំណើតទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម

### មាត្រា៤.- វិធានដើមកំណើតទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីឬកិច្ចព្រមព្រៀងពាណិជ្ជកម្មនានា

ការកំណត់ដើមកំណើតទំនិញដើម្បីទទួលបានប្រព្រឹត្តកម្មអនុគ្រោះពន្ធ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីឬកិច្ចព្រមព្រៀងពាណិជ្ជកម្មនានា ត្រូវអនុវត្តដោយអនុលោមតាមវិធានដើមកំណើតទំនិញក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីឬកិច្ចព្រមព្រៀងពាណិជ្ជកម្មនានា ដែលព្រះរាជាណាចក្រកម្ពុជាជាភាគី។

### មាត្រា៥.- វិធានដើមកំណើតទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មជាឯកតោភាគី

ការកំណត់ដើមកំណើតទំនិញដើម្បីទទួលបានប្រព្រឹត្តកម្មអនុគ្រោះពន្ធ ក្នុងក្របខ័ណ្ឌនៃការផ្តល់ភាពអនុគ្រោះជាឯកតោភាគី ត្រូវអនុវត្តដោយអនុលោមតាមវិធានដើមកំណើតទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មនៃប្រទេសនាំចូល។

# ជំពូកទី៣
# វិធានដើមកំណើតទំនិញក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម

**មាត្រា៦ _ ការកំណត់ដើមកំណើតទំនិញ**

ការកំណត់ដើមកំណើតទំនិញ ត្រូវផ្អែកលើលក្ខណវិនិច្ឆ័យដូចខាងក្រោមៈ

- ទំនិញដែលទទួលបានទាំងស្រុងឬផលិតទាំងស្រុងនៅប្រទេសមួយ ឬ
- ការកែច្នៃជាសារវន្ត។

ទំនិញដែលទទួលបានឬផលិតទាំងស្រុងនៅក្នុងប្រទេសមួយ ត្រូវចាត់ទុកថាមានដើមកំណើតនៅប្រទេសនោះ។ ទំនិញដែលត្រូវបានចាត់ទុកថាជាទំនិញដែលទទួលបានទាំងស្រុងឬផលិតទាំងស្រុងនៅក្នុងប្រទេសមួយ មានដូចខាងក្រោមៈ

ក- ផលិតផលរ៉ែ រួមទាំងប្រេងកាតដែលទាញយកចេញពីក្នុងដី ដែនទឹក ឬពីក្រោមបាតសមុទ្រនៃប្រទេសនោះ។

ខ- រុក្ខជាតិនិងផលិតផលរុក្ខជាតិដែលបានប្រមូលផលនិងប្រមូលទុកនៅប្រទេសនោះ។

គ- សត្វរស់ដែលបានកើតនិងបានចិញ្ចឹមនៅប្រទេសនោះ។

ឃ- ទំនិញបានមកពីសត្វរស់ដែលបានចិញ្ចឹមនៅក្នុងប្រទេសនោះ។

ង- ទំនិញបានមកពីការប្រមាញ់ឬការនេសាទនៅក្នុងប្រទេសនោះ។

ច- ទំនិញបានមកពីការនេសាទសមុទ្រនិងបណ្តាទំនិញក្នុងសមុទ្រដទៃទៀតដែលត្រូវបានយកពីសមុទ្រ ដោយនាវាដាក់ទង់ជាតិនៃប្រទេសនោះ។

ឆ- ទំនិញបានមកទាំងស្រុងពីនាវារោងចក្រនៃប្រទេសនោះ ចេញពីទំនិញដែលមានចែងក្នុងចំណុច ច ខាងលើ។

ជ- ទំនិញដែលទាញយកចេញពីដីសមុទ្រឬបាតសមុទ្រនៅក្រៅដែនទឹករបស់ប្រទេសនោះ ក្នុងលក្ខខណ្ឌដែលប្រទេសនោះមានសិទ្ធិផ្តាច់មុខក្នុងការទាញយកពីក្នុងដីសមុទ្រឬបាតសមុទ្រនោះ។

ឈ- កម្ទេចកម្ទីឬកាកសំណល់បានមកពីផលិតកម្មនិងដំណើរការផលិត និងបំណែកភាគប្រើប្រាស់រួចដែលបានប្រមូលនៅក្នុងប្រទេសនោះ និងសមស្របសម្រាប់តែគោលបំណងក្នុងការទាញយកមកប្រើប្រាស់ឡើងវិញជាវត្ថុធាតុដើម។

ញ- ទំនិញត្រូវបានផលិតទាំងស្រុងនៅក្នុងប្រទេសនោះចេញពីទំនិញដែលមានចែងក្នុងចំណុច ក ដល់ចំណុច ឈ ខាងលើ។

ក្នុងករណីប្រទេសច្រើនពាក់ព័ន្ធក្នុងដំណើរការផលិតទំនិញ ការកំណត់ដើមកំណើតទំនិញ ត្រូវផ្អែកលើលក្ខណវិនិច្ឆ័យនៃការកែច្នៃជាសារវន្ត។ ការកំណត់ដើមកំណើតទំនិញដោយលក្ខណវិនិច្ឆ័យនៃការកែច្នៃជាសារវន្ត ត្រូវធ្វើឡើងតាមការផ្លាស់ប្តូរចំណាត់ថ្នាក់ទំនិញតាមតារាងពន្ធគយ ឬវិធានភាគរយតម្លៃបន្ថែម។

លក្ខណៈបច្ចេកទេសលម្អិតនៃការកែច្នៃជាសារវន្ត ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**មាត្រា៧ _ ប្រតិបត្តិការនិងការកែច្នៃអប្បបរមា**

ប្រតិបត្តិការដូចខាងក្រោមដែលប្រព្រឹត្តចំពោះវត្ថុធាតុមិនមានដើមកំណើត ដើម្បីផលិតទំនិញមួយ ត្រូវចាត់ទុកថាជាប្រតិបត្តិការឬការកែច្នៃមិនមានភាពគ្រប់គ្រាន់ក្នុងការផ្តល់ដើមកំណើតទំនិញដល់ទំនិញនោះឡើយ៖

១- ប្រតិបត្តិការចាំបាច់សម្រាប់ការថែរក្សាទុកទំនិញ អំឡុងពេលដឹកជញ្ជូនឬរក្សាទុក។

២- ប្រតិបត្តិការដើម្បីធ្វើឱ្យប្រសើរឡើងនូវការវេចខ្ចប់ ឬគុណភាពទំនិញឆ្លើយតបនឹងទីផ្សារ ឬដើម្បីរៀបចំសម្រាប់ការដឹកជញ្ជូនទំនិញ ដូចជាការបំបែកជាដុំៗ ការដាក់តម្រៀបជាក្រុមនិងការចាត់ថ្នាក់នៃកញ្ចប់ និងការវេចខ្ចប់ឡើងវិញជាដើម។

៣- ការផ្គុំដំឡើងសាមញ្ញ។

៤- ការលាយទំនិញដែលមានដើមកំណើតទំនិញខុសៗគ្នា ក្នុងលក្ខខណ្ឌដែលលក្ខណៈនៃទំនិញទទួលបាន មិនមានភាពខុសប្លែកខ្លាំងពីលក្ខណៈនៃទំនិញដែលបានលាយបញ្ចូលគ្នា។

៥- ប្រតិបត្តិការឬដំណើរការផ្សេងទៀតត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដោយអនុលោមតាមបច្ចុប្បន្នភាពចុងក្រោយនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនិងកិច្ចព្រមព្រៀងពាណិជ្ជកម្មផ្សេងទៀត ឬស្ថាប័នអន្តរជាតិនានា។

**មាត្រា៨ _ ការដឹកជញ្ជូនត្រង់**

ទំនិញអាចរក្សាស្ថានភាពដើមកំណើត ដូចមានចែងក្នុងមាត្រា៦នៃច្បាប់នេះ ប្រសិនបើបំពេញបានតាមលក្ខខណ្ឌដូចខាងក្រោម៖

១- ទំនិញនោះត្រូវបានដឹកជញ្ជូនត្រង់ពីប្រទេសដើមកំណើតទៅប្រទេសនាំចូល។

២- ទំនិញត្រូវបានដឹកជញ្ជូនឆ្លងកាត់ប្រទេសអន្តរការី ប្រសិនបើទំនិញនោះមិនបានឆ្លងកាត់ការកែប្រែឬកែច្នៃណាមួយបន្ថែមក្នុងប្រទេសអន្តរការីនោះ ក្រៅពីសកម្មភាពភស្តុភារកម្ម មានដូចជាការលើកដាក់ ការស្តុកទុក ឬប្រតិបត្តិការចាំបាច់ផ្សេងៗ ក្នុងការថែរក្សាឬដឹកជញ្ជូនទំនិញនោះទៅកាន់ប្រទេសនាំចូល។

## ជំពូកទី៤
## សំអាងដើមកំណើតទំនិញនិងស្លាកសញ្ញាសម្គាល់ដើមកំណើតផលិតផល

**មាត្រា៩ _ សំអាងដើមកំណើតទំនិញ**

វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់ជាក្រដាសឬទម្រង់អេឡិចត្រូនិក និងប្រតិវេទន៍ដើមកំណើតទំនិញ ត្រូវបានចាត់ទុកជាសំអាងដើមកំណើតទំនិញ។ សំអាងដើមកំណើតទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ត្រូវអនុវត្តដោយអនុលោមតាមលក្ខខណ្ឌតម្រូវវិធានដើមកំណើតទំនិញក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីឬកិច្ចព្រមព្រៀងពាណិជ្ជកម្មនានា ដែលព្រះរាជាណាចក្រកម្ពុជាជាភាគី។ សំអាងដើមកំណើតទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ក្នុងក្របខ័ណ្ឌនៃការផ្តល់ភាពអនុគ្រោះជាឯកតោភាគី ត្រូវអនុវត្តអនុលោមតាមបទប្បញ្ញត្តិស្តីពីវិធានដើមកំណើតទំនិញរបស់ប្រទេសនាំចូល។

វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ត្រូវមានភ្ជាប់ជាមួយព័ត៌មានអប្បបរមានិងតាមទម្រង់របស់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មនៃទំនិញនាំចេញ ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**មាត្រា១០ _ លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ព័ត៌មានសម្គាល់ដើមកំណើតផលិតផលក្រោមវិធានដើមកំណើតទំនិញ**

លក្ខខណ្ឌនិងនីតិវិធីក្នុងការផ្តល់ព័ត៌មានសម្គាល់ដើមកំណើតផលិតផល ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដោយអនុលោមតាមវិធានដើមកំណើតទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មរបស់ប្រទេសនាំចូល ឬក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដែលព្រះរាជាណាចក្រកម្ពុជាជាភាគី និងលក្ខណវិនិច្ឆ័យដើមកំណើតទំនិញ ដូចមានចែងក្នុងមាត្រា៦នៃច្បាប់នេះ។

**មាត្រា១១ _ យថាភូតភាពនៃវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ**

វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មនិងវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ក្នុងទម្រង់ជាក្រដាសដែលមានយថាភូតភាព ត្រូវមានហត្ថលេខាទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ចនិងត្រាផ្លូវការរបស់អាជ្ញាធរចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ឬការសម្គាល់យថាភូតភាពតាមមធ្យោបាយផ្សេងទៀតតាមការកំណត់របស់អាជ្ញាធរ ឬស្ថាប័នមានសមត្ថកិច្ចចេញវិញ្ញាបនបត្រនៃប្រទេសនាំចេញ។

ក្នុងករណីវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទាំងនោះ ត្រូវបានចេញជាទម្រង់អេឡិចត្រូនិកដោយអាជ្ញាធរចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញឬស្ថាប័នមានសមត្ថកិច្ចចេញវិញ្ញាបនបត្រនៃប្រទេសនាំចេញ ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនិងកិច្ចព្រមព្រៀងពាណិជ្ជកម្មនានា ដែលព្រះរាជាណាចក្រកម្ពុជានិងប្រទេសនាំចូលជាភាគី ឬនៃប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មជាឯកតោភាគី ឬនៃច្បាប់និងបទប្បញ្ញត្តិជាធរមាន។

នីតិវិធីក្នុងការកំណត់យថាភូតភាពនៃវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់អេឡិចត្រូនិកដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**មាត្រា១២ _ តម្រូវការរក្សាទុកឯកសារ**

បុគ្គលដែលជាផលិតករ អ្នកនាំចេញត្រូវរក្សាទុកសំណុំឯកសារសំអាងដើមកំណើតទំនិញនៅទីកន្លែងធុរកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា រយៈពេល៣(បី)ឆ្នាំ សម្រាប់ធ្វើអធិការកិច្ចនិងការត្រួតពិនិត្យរបស់មន្ត្រីមានសមត្ថកិច្ចក្រសួងពាណិជ្ជកម្ម។

បុគ្គលដែលជាផលិតករ អ្នកនាំចេញ ឬអ្នកនាំចូល ត្រូវរក្សាទុកសំណុំឯកសារសំអាងដើមកំណើតទំនិញនៅទីកន្លែងធុរកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមច្បាប់ស្តីពីគយ សម្រាប់ធ្វើអធិការកិច្ចនិងការត្រួតពិនិត្យរបស់រដ្ឋបាលគយ។

ឯកសារពាក់ព័ន្ធដូចមានចែងក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី២នៃមាត្រានេះ អាចរក្សាទុកក្នុងឧបករណ៍ផ្ទុកណាមួយ ដែលអាចទាញទិន្នន័យវិញបានភ្លាមៗ រួមមានទម្រង់អេឡិចត្រូនិកឬតាមទម្រង់ជាក្រដាស ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា១៣.- ការក្លែងបន្លំដើមកំណើតទំនិញ**

បុគ្គលមិនត្រូវប្រព្រឹត្តឬប៉ុនប៉ងប្រព្រឹត្តដោយចេតនានូវអំពើក្លែងបន្លំដើមកំណើតទំនិញ ដើម្បីទទួលបានប្រព្រឹត្តកម្មអនុគ្រោះពន្ធ ឬដើម្បីគេចវេះពន្ធប្រឆាំងការលក់បង្ខូចថ្លៃ ឬពន្ធប៉ះប៉ូវអនុវត្តនៅប្រទេសនាំចូល។

ត្រូវបានហាមឃាត់អំពើក្លែងបន្លំដើមកំណើតទំនិញដូចខាងក្រោម៖

១- ការក្លែងសំអាងដើមកំណើតទំនិញ ឬ

២- ការក្លែងព័ត៌មានលើសំអាងដើមកំណើតទំនិញ។

**មាត្រា១៤.- ការមិនអនុលោមក្នុងការស្នើសុំបញ្ជាក់ដើមកំណើតទំនិញ**

បុគ្គលមិនត្រូវប្រព្រឹត្តដោយចេតនានូវអំពើមិនអនុលោមក្នុងការស្នើសុំបញ្ជាក់ដើមកំណើតទំនិញទ្បើយ។

ត្រូវបានហាមឃាត់អំពើមិនអនុលោមក្នុងការស្នើសុំបញ្ជាក់ដើមកំណើតទំនិញដូចខាងក្រោម៖

១- ការប្រកាសប្រភពទំនិញមិនត្រឹមត្រូវ។

២- ការប្រកាសវត្ថុធាតុដើមសម្រាប់ផលិតទំនិញមិនត្រឹមត្រូវ។

៣- ការផ្តល់ព័ត៌មានអំពីតម្លៃលើវិក្កយបត្រនាំចូលវត្ថុធាតុដើមមិនត្រឹមត្រូវ។

៤- ការផ្តល់ព័ត៌មានអំពីតម្លៃលើវិក្កយបត្រនាំចេញទំនិញមិនត្រឹមត្រូវ។

៥- ការចាត់ថ្នាក់ទំនិញមិនត្រឹមត្រូវ។

៦- ការផ្តល់ព័ត៌មានអំពីលក្ខណវិនិច្ឆ័យដើមកំណើតទំនិញមិនត្រឹមត្រូវ។

៧- ការផ្តល់របាយការណ៍ផលិតភាពមិនត្រឹមត្រូវ។

៨- ការផ្តល់ព័ត៌មានអំពីមធ្យោបាយផលិតកម្មមិនត្រឹមត្រូវ។

៩- ការផ្តល់ព័ត៌មានអំពីតម្លៃចំណាយមិនត្រឹមត្រូវ។

**មាត្រា១៥.- ការលើកលែងសំអាងដើមកំណើតទំនិញ**

ការលើកលែងសំអាងដើមកំណើតទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ត្រូវអនុវត្តតាមបញ្ញត្តិក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីឬកិច្ចព្រមព្រៀងពាណិជ្ជកម្មនានា ដែលព្រះរាជាណាចក្រកម្ពុជាជាភាគី ឬតាមបញ្ញត្តិក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មជាឯកតោភាគី។

សំអាងដើមកំណើតទំនិញក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ត្រូវបានលើកលែងចំពោះ៖

១- ទំនិញនាំចេញ លើកលែងតែមានការតម្រូវពីប្រទេសនាំចូល ឬតាមការស្នើសុំរបស់អ្នកនាំចេញ។

២- ទំនិញនាំចូល លើកលែងតែមានការចាំបាច់ក្នុងការប្រើប្រាស់សម្រាប់ការអនុវត្តវិធានការពាណិជ្ជកម្ម ឬវិធានការសម្រាប់គោលបំណងការពារសុខុមាលភាពនិងសុវត្ថិភាពសាធារណៈដោយព្រះរាជាណាចក្រកម្ពុជា។

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL

# ជំពូកទី៥
# អាជ្ញាធរមានសមត្ថកិច្ច
## ផ្នែកទី១
## អាជ្ញាធរចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ

**មាត្រា១៦ .-** អាជ្ញាធរចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ

ក្រសួងពាណិជ្ជកម្ម ដែលមានអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្មឬអង្គភាពផ្សេងទៀត ដែលទទួលបានសិទ្ធិពីក្រសួងពាណិជ្ជកម្ម ជាអាជ្ញាធរចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ទាំងទម្រង់ជាក្រដាស និងទម្រង់អេឡិចត្រូនិក។ ក្រសួងពាណិជ្ជកម្ម ជាស្ថាប័នគ្រប់គ្រងនិងផ្តល់នីតិសម្បទាដល់អ្នកនាំចេញដែលមានការទទួលស្គាល់ ក្នុងការបញ្ជាក់ដើមកំណើតទំនិញដោយខ្លួនឯង។

នីតិវិធីក្នុងការស្នើសុំនិងផ្តល់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**មាត្រា១៧ .-** ការរក្សាទុកឯកសារដោយអាជ្ញាធរចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ

អាជ្ញាធរចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ត្រូវរក្សាទុកឯកសារ កំណត់ត្រា និងព័ត៌មានពាក់ព័ន្ធនឹងវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទទួលបានដើមកំណើត ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ឯកសារពាក់ព័ន្ធដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ អាចរក្សាទុកក្នុងឧបករណ៍ផ្ទុកឬមធ្យោបាយណាមួយដែលអាចទាញទិន្នន័យវិញបានភ្លាមៗ រួមមានទម្រង់អេឡិចត្រូនិកឬទម្រង់ជាក្រដាស ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា១៨ .-** ការផ្ទៀងផ្ទាត់

ក្រសួងពាណិជ្ជកម្មមានសមត្ថកិច្ចក្នុងការពិនិត្យផ្ទៀងផ្ទាត់ជាលក្ខណៈប្រតិសកម្មលើវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ឬប្រតិវេទន៍ដើមកំណើតទំនិញ ចំពោះទំនិញនាំចេញពីកម្ពុជា តាមការចាំបាច់ ឬតាមសំណើរបស់អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនាំចូល ដែលមានការសង្ស័យចំពោះយថាភូតភាពនៃឯកសារឬសុក្រឹតភាពនៃព័ត៌មានទាក់ទងនឹងដើមកំណើតទំនិញដែលមានការសង្ស័យ ឬផ្នែកណាមួយនៃព័ត៌មានឬឯកសារនៃទំនិញនាំចេញនោះ។

តាមសំណើរបស់ក្រសួងពាណិជ្ជកម្ម អ្នកនាំចេញត្រូវផ្តល់ព័ត៌មានឬឯកសារពាក់ព័ន្ធនឹងដើមកំណើតទំនិញមកក្រសួងពាណិជ្ជកម្ម ដើម្បីធ្វើការពិនិត្យផ្ទៀងផ្ទាត់ជាលក្ខណៈប្រតិសកម្មតាមការកំណត់។

## ផ្នែកទី២
## អាជ្ញាធរទទួលសំអាងដើមកំណើតទំនិញ

**មាត្រា១៩ .-** អាជ្ញាធរទទួលសំអាងដើមកំណើតទំនិញ

រដ្ឋបាលគយជាអាជ្ញាធរទទួលសំអាងដើមកំណើតទំនិញទាំងក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ផ្តល់ដោយអ្នកនាំចូល ផលិតករ ឬតំណាង ដែលទទួលបានសិទ្ធិ។ នីតិវិធីក្នុងការទទួលសំអាងដើមកំណើតទំនិញសម្រាប់ទំនិញនាំចូល ត្រូវអនុលោមតាមច្បាប់ស្តីពីគយនិងបទប្បញ្ញត្តិគតិយុត្តជាធរមាន។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា២០.- ការផ្ទៀងផ្ទាត់**

រដ្ឋបាលគយមានសមត្ថកិច្ចក្នុងការពិនិត្យផ្ទៀងផ្ទាត់ជាលក្ខណៈប្រតិសកម្មនូវសំអាងដើមកំណើតទំនិញ ដែលបានបង្ហាញនៅពេលនាំចូល ចំពោះយថាភូតភាពនៃឯកសារឬសុក្រឹតភាពនៃព័ត៌មានទាក់ទងនឹងដើមកំណើតទំនិញ។ រដ្ឋបាលគយមានសិទ្ធិតម្រូវឱ្យអ្នកនាំចូល ផ្តល់ព័ត៌មានឬឯកសារពាក់ព័ន្ធនឹងដើមកំណើតទំនិញ ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

រដ្ឋបាលគយអាចស្នើសុំកិច្ចសហការពីអាជ្ញាធរឬស្ថាប័នចេញសំអាងដើមកំណើតទំនិញនៃប្រទេសដើមកំណើតឬប្រទេសនាំចេញ ដើម្បីធ្វើការផ្ទៀងផ្ទាត់ជាលក្ខណៈប្រតិសកម្ម។

## ជំពូកទី៦
## មន្ត្រីមានសមត្ថកិច្ចនិងនីតិវិធីនៃការស៊ើបអង្កេត

**មាត្រា២១.- ការស៊ើបអង្កេតដើមកំណើតទំនិញសម្រាប់ទំនិញនាំចេញ**

ក្រសួងពាណិជ្ជកម្មមានសមត្ថកិច្ចធ្វើការស៊ើបអង្កេតលើដើមកំណើតទំនិញនាំចេញ។

ការស៊ើបអង្កេតដើមកំណើតទំនិញនាំចេញ ត្រូវធ្វើឡើងតែក្នុងករណីជាប់ពាក់ព័ន្ធការក្លែងបន្លំដើមកំណើតទំនិញ ដើម្បីទទួលបានអត្រាពន្ធអនុគ្រោះនៅប្រទេសនាំចូល ឬផលប្រយោជន៍នានា ឬដើម្បីគេចវេះពីវិធានការប្រឆាំងការលក់បង្ខូចថ្លៃ វិធានការប៉ះប៉ូវ និងវិធានការការពារ។

ការស៊ើបអង្កេតលើដើមកំណើតទំនិញនាំចេញ ត្រូវធ្វើឡើងតាមរយៈការចុះពិនិត្យទីតាំងខ្សែច្រវាក់ផលិតកម្ម ឯកសារ បញ្ជីគណនេយ្យ កំណត់ត្រា និងព័ត៌មានផ្សេងទៀត ដែលទាក់ទងនឹងដើមកំណើតទំនិញ។ នីតិវិធីនៃការស៊ើបអង្កេតដើមកំណើតទំនិញនាំចេញ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**មាត្រា២២.- មន្ត្រីស៊ើបអង្កេតដើមកំណើតទំនិញសម្រាប់ទំនិញនាំចេញ**

មន្ត្រីស៊ើបអង្កេតត្រូវជ្រើសរើសចេញពីអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម តាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដើម្បីពិនិត្យបទល្មើសនៅក្នុងច្បាប់នេះ។

**មាត្រា២៣.- នីតិវិធីនៃការផ្តល់នីតិសម្បទា**

មន្ត្រីស៊ើបអង្កេតទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ ឱ្យពិនិត្យបទល្មើសដែលមានចែងក្នុងច្បាប់នេះស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ចំពោះមន្ត្រីស៊ើបអង្កេតដើមកំណើតទំនិញនាំចេញ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**មាត្រា២៤.- សិទ្ធិរបស់មន្ត្រីស៊ើបអង្កេត**

មន្ត្រីស៊ើបអង្កេតដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌មានសិទ្ធិពិនិត្យ ស្រាវជ្រាវ ស៊ើបអង្កេត កោះហៅនិងស្តាប់ចម្លើយ ឆែកឆេរ ចាប់យកវត្ថុតាង និងប្រមូលទិន្នន័យ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសក្រោមច្បាប់នេះដោយអនុវត្តតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

មន្ត្រីស៊ើបអង្កេតមានសិទ្ធិស្នើសុំជំនួយពីអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ និងអង្គភាពប្រដាប់អាវុធ ឬអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធផ្សេងៗទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើសដែលមានចែងក្នុងច្បាប់នេះ។

**មាត្រា២៥ .- ការស្តាប់ចម្លើយសាក្សី**

មន្ត្រីស៊ើបអង្កេតអាចស្តាប់ចម្លើយសាក្សីណាមួយបាន ប្រសិនបើមន្ត្រីស៊ើបអង្កេតនោះយល់ឃើញថា សក្ខីកម្មរបស់សាក្សីអាចមានប្រយោជន៍ដល់ការស៊ើបអង្កេត ដោយអនុវត្តតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ក្នុងករណីសាក្សីណាមួយបដិសេធមិនចូលខ្លួនដោយគ្មានមូលហេតុ ធ្វើឱ្យប៉ះពាល់ដល់ដំណើរការស៊ើបអង្កេត ស្វែងរកបទល្មើស មន្ត្រីស៊ើបអង្កេតអាចស្នើសុំទៅព្រះរាជអាជ្ញាមានសមត្ថកិច្ចបញ្ជាឱ្យសាក្សីរូបនោះចូលខ្លួនផ្តល់ចម្លើយចំពោះមុខមន្ត្រីស៊ើបអង្កេត។

**មាត្រា២៦ .- ការស៊ើបអង្កេតដើមកំណើតទំនិញសម្រាប់ទំនិញនាំចូល**

ការស៊ើបអង្កេតដើមកំណើតទំនិញនាំចូលចំពោះករណីពាក់ព័ន្ធនឹងការក្លែងបន្លំដើមកំណើតទំនិញ ដើម្បីទទួលបានប្រព្រឹត្តកម្មពន្ធអនុគ្រោះ ឬផលប្រយោជន៍នានា ឬដើម្បីគេចវេះពីវិធានការប្រឆាំងការលក់បង្ខូចថ្លៃ វិធានការប៉ះប៉ូវ និងវិធានការការពារ ជាសមត្ថកិច្ចរបស់មន្ត្រីគយដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ ដោយអនុវត្តស្របតាមច្បាប់នេះ ច្បាប់ស្តីពីគយនិងបទប្បញ្ញត្តិជាធរមាន។

**មាត្រា២៧ .- ការស៊ើបអង្កេតរួមលើដើមកំណើតទំនិញ**

ក្នុងករណីចាំបាច់ ក្រសួងពាណិជ្ជកម្មឬរដ្ឋបាលគយអាចស្នើសុំកិច្ចសហការពីស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការស៊ើបអង្កេតរួម។

## ជំពូកទី៧
## ទោសប្បញ្ញត្តិ

**មាត្រា២៨ .- ទណ្ឌកម្ម**

ទណ្ឌកម្មនៅក្នុងច្បាប់នេះ រួមមានទណ្ឌកម្មរដ្ឋបាលនិងទណ្ឌកម្មព្រហ្មទណ្ឌ៖

ទណ្ឌកម្មរដ្ឋបាល រួមមាន៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការផ្អាកជាបណ្តោះអាសន្នឬការបញ្ឈប់សកម្មភាពប្រតិបត្តិការអាជីវកម្ម
- ការព្យួរ ការដកហូត ឬការលុបចោលលិខិតអនុញ្ញាតឬអាជ្ញាបណ្ណ។

ការព្រមានជាលាយលក្ខណ៍អក្សរ ការផ្អាកជាបណ្តោះអាសន្ន ឬការបញ្ឈប់សកម្មភាពប្រតិបត្តិការអាជីវកម្ម ការព្យួរ ការដកហូត ឬការលុបចោលលិខិតអនុញ្ញាតឬអាជ្ញាបណ្ណ ជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម។

អំពើល្មើសដែលត្រូវទទួលរងទណ្ឌកម្មរដ្ឋបាលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

បុគ្គលដែលមិនសុខចិត្តចំពោះការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាលអាចដាក់ពាក្យប្តឹងតវ៉ាទៅរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបានការសម្រេចពីការដាក់ទណ្ឌកម្មនោះ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មត្រូវធ្វើសេចក្តីសម្រេចចំពោះបណ្តឹងតវ៉ាក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបានពាក្យបណ្តឹងតវ៉ា។

ក្នុងករណីដែលបុគ្គលនោះនៅតែមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បុគ្គលនោះអាចដាក់ពាក្យប្តឹងទៅតុលាការ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើបណ្តឹងតវ៉ានោះ។

ប្រភេទទណ្ឌកម្មរដ្ឋបាល សមត្ថកិច្ច និងនីតិវិធីនៃការប្តឹងតវ៉ាចំពោះការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាលពាក់ព័ន្ធនឹងដើមកំណើតទំនិញនាំចូល ត្រូវអនុវត្តស្របតាមច្បាប់ស្តីពីគយនិងបទប្បញ្ញត្តិជាធរមាន។

ទណ្ឌកម្មព្រហ្មទណ្ឌ រួមមាន៖

- ការពិន័យអន្តរការណ៍
- ការពិន័យជាប្រាក់
- ទោសដាក់ពន្ធនាគារ។

អំពើល្មើសផ្សេងទៀតដែលត្រូវពិន័យអន្តរការណ៍ស្របតាមច្បាប់នេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

ការសម្រេចដាក់ពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់មន្ត្រីស៊ើបអង្កេតនិង/ឬមន្ត្រីគយ ដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌។

ការបង់ប្រាក់ពិន័យអន្តរការណ៍ នាំឱ្យរំលត់បណ្តឹងអាជ្ញា។

ការបង់ប្រាក់ពិន័យអន្តរការណ៍ មិននាំឱ្យរួចផុតពីកាតព្វកិច្ចអនុវត្តវិធានការរដ្ឋបាលនិងទណ្ឌកម្មរដ្ឋបាលផ្សេងទៀតដែលបានដាក់ចេញស្របតាមច្បាប់នេះឡើយ។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ មន្ត្រីស៊ើបអង្កេតនិង/ឬមន្ត្រីគយដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការមានសមត្ថកិច្ច។

បែបបទនិងនីតិវិធីនៃការពិន័យអន្តរការណ៍សម្រាប់អំពើល្មើសពាក់ព័ន្ធនឹងដើមកំណើតទំនិញនាំចេញ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ចំពោះបែបបទនិងនីតិវិធីនៃការពិន័យអន្តរការណ៍សម្រាប់អំពើល្មើសពាក់ព័ន្ធនឹងដើមកំណើតទំនិញនាំចូល ត្រូវអនុវត្តស្របតាមច្បាប់ស្តីពីគយនិងបទប្បញ្ញត្តិជាធរមាន។

ការបង់ប្រាក់ពិន័យអន្តរការណ៍ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យអន្តរការណ៍ និងការចាត់ចែងប្រាក់ចំណូលដែលបានពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសពាក់ព័ន្ធនឹងដើមកំណើតទំនិញនាំចេញដូចមានចែងស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២៩ _ ការមិនរក្សាទុកឯកសារ**

បុគ្គលទាំងឡាយមិនបានរក្សាទុកសំណុំឯកសារសំអាងដើមកំណើតទំនិញដូចមានកំណត់ក្នុងកថាខណ្ឌទី១ នៃមាត្រា១២ នៃច្បាប់នេះ ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ។ ក្នុងករណីមិនអនុវត្តតាមការព្រមានជាលាយលក្ខណ៍អក្សរ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី១ ០០០ ០០០(មួយលាន)រៀលទៅ១០ ០០០ ០០០(ដប់លាន)រៀល។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា៣០ ._ ការប្រព្រឹត្តអំពើមិនអនុលោមក្នុងការស្នើសុំបញ្ជាក់ដើមកំណើតទំនិញ**

ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើមិនអនុលោមក្នុងការស្នើសុំបញ្ជាក់ដើមកំណើតទំនិញ ដូចមានចែងក្នុងមាត្រា១៤ នៃច្បាប់នេះ។

ក្នុងករណីទទួលការព្រមានជាលាយលក្ខណ៍អក្សរដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះម្តងរួចហើយ ហើយបុគ្គលនេះនៅតែបន្តប្រព្រឹត្តអំពើមិនអនុលោមក្នុងការស្នើសុំបញ្ជាក់ដើមកំណើតទំនិញទៀត ត្រូវផ្អាកជាបណ្តោះអាសន្ននូវសកម្មភាពប្រតិបត្តិការអាជីវកម្ម។

ក្នុងករណីដែលសកម្មភាពប្រតិបត្តិការអាជីវកម្មត្រូវបានផ្អាកជាបណ្តោះអាសន្ន ដូចមានចែងក្នុងកថាខណ្ឌទី២ខាងលើនេះរួចហើយ ហើយបុគ្គលនេះនៅតែបន្តប្រព្រឹត្តអំពើមិនអនុលោមក្នុងការស្នើសុំបញ្ជាក់ដើមកំណើតទំនិញទៀត ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី១ ០០០ ០០០(មួយលាន)រៀល ទៅ ២០ ០០០ ០០០(ម្ភៃលាន)រៀល។

ប្រាក់ពិន័យអន្តរការណ៍ត្រូវកើនឡើងទ្វេដង ក្នុងករណីបុគ្គលដែលទទួលការពិន័យអន្តរការណ៍ម្តងរួចហើយនៅតែបន្តប្រព្រឹត្តអំពើមិនអនុលោមក្នុងការស្នើសុំបញ្ជាក់ដើមកំណើតទំនិញទៀត។

បុគ្គលដែលទទួលការពិន័យអន្តរការណ៍ទ្វេដង ដូចមានចែងក្នុងកថាខណ្ឌទី៤ នៃមាត្រានេះរួចហើយ ហើយនៅតែបន្តប្រព្រឹត្តអំពើមិនអនុលោមក្នុងការស្នើសុំបញ្ជាក់ដើមកំណើតទំនិញទៀតត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី១ ០០០ ០០០(មួយលាន)រៀលទៅ ២០ ០០០ ០០០(ម្ភៃលាន)រៀល។

**មាត្រា៣១ ._ ការប្រព្រឹត្តអំពើក្លែងបន្លំដើមកំណើតទំនិញ**

បុគ្គលទាំងឡាយដែលប្រព្រឹត្តអំពើផ្ទុយនឹងមាត្រា១៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំទៅ៥(ប្រាំ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀលទៅ៤០ ០០០ ០០០ (សែសិបលាន)រៀល។

**មាត្រា៣២ ._ ការទទួលខុសត្រូវរបស់នីតិបុគ្គល**

នីតិបុគ្គលអាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា៣០ និងមាត្រា៣១នៃច្បាប់នេះ។

នីតិបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា៣០និងមាត្រា៣១ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨(ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ។

**មាត្រា៣៣ ._ ការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត**

ក្នុងការអនុវត្តបទប្បញ្ញត្តិនៃជំពូកទី៧ នៃច្បាប់នេះ មិនរារាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀតក្នុងករណីដែលអំពើដែលកំណត់ថាជាបទល្មើសដែលមានចែងក្នុងច្បាប់នេះ ជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ព្រហ្មទណ្ឌផ្សេងទៀត។

ROYAUME DU CAMBODGE ★ LE MINISTRE DU PALAIS ROYAL

## ជំពូកទី៨
## អន្តរប្បញ្ញត្តិ

**មាត្រា៣៤.-** ការបន្តសុពលភាពវិញ្ញាបនបត្រ

វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញដែលបានចេញមុនច្បាប់នេះចូលជាធរមាន ត្រូវបន្តមានសុពលភាពដដែល។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា៣៥.-** ការទុកជានិរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

ថ្ងៃ អង្គារ ៣រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០២៣

០៧២៣-ម៉ោង០៧-១៤០០

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**